- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- **បានឃើញអនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស តាយសេងបាវិត**
- **បានឃើញសេចក្តីជូនដំណឹងលេខ ២៦៨ សជណ.សរ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីលទ្ធផលនៃសម័យប្រជុំច្រកចេញ-ចូលតែមួយនៃគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា**
- **យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

សំរេច

ប្រការ ១.- បង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស តាយសេងបាវិត ដែលមានទីតាំងស្ថិតនៅឃុំច្រកម្ទេស ស្រុកស្វាយទាប និងឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង ដែលមានសមាសភាពដូចខាងក្រោម :

១-តំណាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា	ប្រធាន
២-តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៣-តំណាងទីចាត់ការគយ និងរដ្ឋាករ	សមាជិក
៤-តំណាងនាយកដ្ឋានត្រួតពិនិត្យចំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំនៃក្រសួងពាណិជ្ជកម្ម	សមាជិក
៥-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក

សមាជិករដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ២.- រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនេះ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

- ត្រួតពិនិត្យតាមមុខជំនាញសមត្ថកិច្ចចំពោះការចេញពី និងចូលមកនូវចំនិញ មធ្យោបាយ និងជនានុជនគ្រប់រូបរបស់តំបន់ ។ អនុវត្តការត្រួតពិនិត្យបែបបទគយ សំរាប់ការចេញចូលចំនិញ និងសំរួលបែបបទរដ្ឋបាលដល់កិច្ចដំណើរការរបស់តំបន់ ជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចជំនាញនានា របស់រាជរដ្ឋាភិបាល ។
- ត្រួតពិនិត្យ ការអនុវត្តន៍ការងាររបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ លើរាល់សកម្មភាពនៅក្នុងតំបន់ ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់ ។

- **ពិនិត្យលើសំណើសុំចុះបញ្ជីវិនិយោគ ពិនិត្យផ្តល់ជូននូវការលើកទឹកចិត្ត ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនប័ត្រប្រភពដើមទំនិញ ដែលស្នើឡើងដោយអ្នកវិនិយោគក្នុងតំបន់ ដើម្បីធ្វើការសំរេចជូនអ្នកវិនិយោគក្នុងតំបន់ នៅនឹងកន្លែង ។**
- ធ្វើការត្រួតពិនិត្យការងារ សកម្មភាពតាមមុខជំនាញនៅក្នុងតំបន់ ។
- សហការជាមួយអ្នកអភិវឌ្ឍន៍តំបន់ ដោះស្រាយការងារដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។
- សំរួលរាល់បែបបទ ដែលពាក់ព័ន្ធ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ។
- ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ឆមាស និងឆ្នាំ ពីសកម្មភាពរបស់តំបន់ជូនក្រសួង-ស្ថាប័នគ្រប់គ្រង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- ធ្វើកិច្ចការផ្សេងៗទៀតក្នុងការសំរបសំរួល ដោះស្រាយរាល់សំណើរបស់អ្នកវិនិយោគក្នុងតំបន់ ពាក់ព័ន្ធទៅនឹងបណ្តាក្រសួង-ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ។

ប្រការ ៣.- គ្រប់តំណាងក្រសួង-ស្ថាប័ន ដែលបំពេញភារកិច្ចនៅក្នុងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស តាយសេង បាវិត ដូចមានចែងក្នុងប្រការ ១ ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទបញ្ជាត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលខេត្តស្វាយរៀង និងក្រុមហ៊ុន តាយ សេង បាវិត អេសអ៊ីហ្សិត ខូអិលធីឌី មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៧



កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..០៦..ប.ប....

បទបញ្ជា

ស្តីពី

ការទប់ស្កាត់ការនាំចូលសាច់ និង សត្វជ្រូករស់ពីបរទេស

ក្នុងពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថាមានចលនានាំចូលសាច់ និង សត្វជ្រូករស់ពីបរទេសមកក្នុងប្រទេសកម្ពុជាតាមគ្រប់រូបភាព និង បែបអាណាធិបតេយ្យក្នុងខណៈដែលប្រទេសមួយចំនួនក្នុងតំបន់ បានផ្ទុះចេញនូវជម្ងឺឆ្លងជ្រូក ។ ចលនានៃការនាំចូលបែបអាណាធិបតេយ្យនេះបានក្លាយជាចលករនៃការផ្តល់លទ្ធភាពដល់ការឆ្លងរាលដាលជម្ងឺជ្រូកនៅកម្ពុជា និងជាការរាំងស្ទះ និងពន្យឺតល្បឿននៃការអភិវឌ្ឍន៍ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ដែលជាផ្នែកមួយសំខាន់ក្នុងការរួមចំណែកដល់ការធ្វើអោយសំរេចបាននូវគោលនយោបាយកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ ។ ពិនិត្យឃើញនូវស្ថានការណ៍មិនអំណោយផលនាពេលបច្ចុប្បន្ន ពិសេសដើម្បីទប់ស្កាត់ការនាំចូលសាច់ និង សត្វជ្រូករស់អោយមានប្រសិទ្ធភាព ក៏ដូចជាសំដៅធ្វើអោយសំរេចបាននូវកិច្ចអភិវឌ្ឍន៍ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារនៅកម្ពុជា រាជរដ្ឋាភិបាលចាំបាច់ដាក់ចេញនូវបទបញ្ជាដូចខាងក្រោម:

១. ក្រសួងអភិផ្ទៃត្រូវបញ្ជាដល់អាជ្ញាធរខេត្ត-ក្រុង ពិសេសខេត្ត-ក្រុង តាមបណ្តោយព្រំដែនអោយចាត់វិធានការបន្ទាន់ក្នុងការទប់ស្កាត់ការនាំចូលសាច់ និង សត្វជ្រូករស់មកក្នុងប្រទេសតាមគ្រប់រូបភាព និងគ្រប់ច្រកទាំងអស់ ។

២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវបញ្ជាដល់មន្ត្រីមានសមត្ថកិច្ចឈរជើងតាមព្រំដែនបញ្ឈប់ការអនុញ្ញាតអោយនាំចូលសាច់ និងសត្វជ្រូករស់មកក្នុងប្រទេសកម្ពុជា ។

៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវចាត់មន្ត្រីជំនាញ ដែលជាមន្ត្រីនគរបាលយុត្តិធម៌ចុះបង្ក្រាបការនាំចូលសាច់ និងសត្វជ្រូករស់នៅទូទាំងប្រទេស ពិសេសនៅតាមគ្រប់ច្រក នៃបណ្តាខេត្ត-ក្រុង តាមព្រំដែន ។

៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវចាត់វិធានការចាប់ ឃាត់ខ្លួន ឬ បំផ្លាញចោលសាច់ ឬ សត្វជ្រូករស់ទៅតាមវិធានបសុពេទ្យ និង នីតិវិធីជាធរមាន ។

៥. ក្រសួងស្ថាប័នពាក់ព័ន្ធ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការនគរបាលជាតិ និងអាជ្ញាធរដែនដី ពិសេសអាជ្ញាធរដែនដី នៃបណ្តាខេត្ត-ក្រុង តាមបណ្តោយព្រំដែន ត្រូវផ្តល់កិច្ចសហការដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អោយបំពេញការងារបានសំរេចតាមបទបញ្ជា ។

៦. ការនាំចូលកូនជ្រូកពូជសំរាប់បំពេញតំរូវការ នៃការចិញ្ចឹមក្នុងស្រុក និង សត្វជ្រូករស់សំរាប់បំរើការពិសោធន៍ស្រាវជ្រាវត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយចាំបាច់ត្រូវត្រួតពិនិត្យអនាម័យ និង សុខភាពសត្វអោយបានត្រឹមត្រូវ ។

ទទួលបានបទបញ្ជានេះ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ទីស្តីការគណៈ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន
- គ្រប់ រាជធានី-ខេត្ត-ក្រុង
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៤៦៥.....សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ២០០៧

រដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅចានាជំណឹរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក. ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែ ដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/៩៦៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/៩២០២/០២ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/៩២០៦/០៣៥, ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០៣ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

- បានឃើញក្រឹត្យលេខ៥៧ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញនាំចូល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលបានប្រកាស ឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ
- បានឃើញពិធីសារស្តីពីការអនុវត្តនាមវលិ នៃតារាងពន្ធគយស៊ីចង្វាក់គ្នារបស់អាស៊ាន ដែលចុះហត្ថលេខា ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធ និងអាករគយលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេស លើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : ដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០០៧ ដូចមានភ្ជាប់ជាមួយនេះ ដែលបានរៀបចំដោយអនុលោមតាមប្រព័ន្ធស៊ីចង្វាក់ នៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ និងស្របទៅតាមតារាងពន្ធគយ នៃប្រព័ន្ធស៊ីចង្វាក់របស់អាស៊ាន (AHTN 2007) ចាប់ពីថ្ងៃទី 09 ខែកក្កដា ឆ្នាំ ២០០៧ តទៅ ។

ប្រការ ២ : រាល់មុខទំនិញនាំចេញ នាំចូលត្រូវជាប់ពន្ធនាំចូល អាករពិសេស អាករលើតម្លៃបន្ថែម និងអាករនាំចេញ ដូចមានចែងលំអិតក្នុងតារាងពន្ធគយនេះ ។

ប្រការ ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ខាងមុខនេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៧

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ជាំង ឈន់

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ខេត្តក្រុង "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្ម
- ទីចាត់ការគយ និងរដ្ឋាករ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

	4411.12.00	- - ដែលមានកំរាស់មិនលើស ៥ ម ម	- - Of a thickness not exceeding 5 mm	kg	15	0	10	0	
	4411.13.00	- - ដែលមានកំរាស់លើស ៥ ម ម ប៉ុន្តែមិនលើស ៩ ម ម	- - Of a thickness exceeding 5 mm but not exceeding 9mm	kg	15	0	10	0	
	4411.14.00	- - ដែលមានកំរាស់លើស ៩ ម ម	- - Of a thickness exceeding 9 mm	kg	15	0	10	0	
		- ផ្សេងទៀត :	- Other :						
	4411.92.00	- - ដែលមានដង់ស៊ីតេលើសពី ០.៨ g/cm^3	- - Of a density exceeding 0.8g/cm^3	kg	15	0	10	0	
	4411.93.00	- - ដែលមានដង់ស៊ីតេលើសពី០.៥ g/cm^3 ប៉ុន្តែមិនលើសពី ០.៨ g/cm^3	- - Of a density exceeding 0.5g/cm^3 but not exceeding 0.8g/cm^3	kg	15	0	10	0	
	4411.94.00	- - ដែលមានដង់ស៊ីតេមិនលើសពី ០.៥ g/cm^3	- - Of a density not exceeding 0.5g/cm^3	kg	15	0	10	0	
44.12		ក្តារបន្ទះ ក្តារឆាសវីនៀរ ក្តារបន្ទះប្រហាក់ប្រហែល ។	**Plywood, veneered panels and similar laminated wood.**						
	4412.10.00	- ពីឫស្សី	- Of bamboo	kg	15	0	10	0	
		- ក្តារបន្ទះដែលមានតែសន្លឹកឈើសុទ្ធ ស្រទាប់និមួយៗមានកំរាស់មិនលើស ៦ម.ម :	- Plywood consisting solely of sheets of wood,each ply not exceeding 6 mm thickness :						
	4412.31.00	- - ដែលមានយ៉ាងហោចណាស់ ស្រទាប់ក្រៅមួយធ្វើពីឈើត្រូពិច ឬចមានចែងនៅក្នុងកំណាត់សំគាល់ទីតាំងរងទី ១ នៃជំពូកនេះ	- - With at least one ply of tropical wood specified in Subheading Note 1 to this Chapter	kg	15	0	10	0	
	4412.32.00	- ផ្សេងៗ ដែលមានយ៉ាងហោចណាស់ស្រទាប់ក្រៅមួយធ្វើពីឈើមិនមែនកូនឈើម្យ៉ា :	- Other, with at least one outer ply of non-coniferous wood :	kg	15	0	10	0	
	4412.39.00	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
		- ផ្សេងទៀត:	- Other:						
	4412.94.00	- - ក្តារចាំង ក្តារបន្ទះស្តើង និងក្តារកំណាត់	- - Blockboard, laminboard and battenboard	kg	15	0	10	0	
	4412.99.00	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
44.13	4413.00.00	ឈើដង់ស៊ីហ្វីយ៉េ ជាពុំ ជាក្តារ ជាបន្ទះ ឬ ជាប្រូហ្វីឡេ	**Densified wood, in blocks, plates, strips or profile shapes.**	kg	15	0	10	0	
44.14	4414.00.00	ក្របធ្វើពីឈើ សម្រាប់ក្តារគំនូរ រូបថត កញ្ចក់ឆ្លុះ ឬវត្ថុប្រហាក់ប្រហែល	**Wooden frames for paintings, photographs, mirrors or similar objects.**	kg	15	0	10	0	

44.15		កេស កេសគ្នូច ប្រអប់ សំបកវេចខ្ចប់ មួលវែង និងសំបកវេចខ្ចប់ប្រហាក់ប្រហែល ធ្វើពីឈើ; បង្គុំសំរាប់ផ្ទៃតាបធ្វើពីឈើ- ប៉ាឡែត- ប៉ាឡែតបម្លែ- ប៉ាឡែត- កេស និងថាសផ្ទុកទំនិញធ្វើពីឈើ ។	**Packing cases, boxes, crates, drums and similar packings, of wood; cable-drums of wood; pallets, box pallets and other load boards, of wood; pallet collars of wood.**						
	4415.10.00	- កេស កេសគ្នូច ប្រអប់ សំបកវេចខ្ចប់ មួលវែង និងសំបកវេចខ្ចប់ប្រហាក់ប្រហែល	- Cases, boxes, crates, drums and similar packings, cable-drums	kg	15	0	10	10	
	4415.20.00	- បង្គុំសំរាប់ តាប ប៉ាឡែត - ប៉ាឡែត- កេស និង ថាសផ្ទុកទំនិញផ្សេងទៀត	- Pallets, box pallets and other load boards ; pallet collars	kg	15	0	10	10	
44.16		ធុងស្រា ធុងឈើ ចាំងឈើតូចៗ និង ផលិតផលធុងឈើផ្សេងទៀត និងផ្នែករបស់វាធ្វើពីឈើ រាប់បញ្ចូលទាំងក្តារ សំបកធុងឈើ ។	**Casks, barrels, vats, tubs and other coopers' products and parts thereof, of wood, including staves.**						
	4416.00.10	- ក្តារសំបកធុងឈើ	- Staves	kg	15	0	10	5	
	4416.00.90	- ផ្សេងទៀត	- Other	kg	15	0	10	5	
44.17	4417.00.00	ប្រដាប់ប្រដាជាងតូ ជងប្រដាប់ប្រដាជាងតូ និងរងអំបោស ឬ ជក់គ្រនាប់សែ្បក ធើងធ្វើពីឈើ ។	**Tools, tool bodies, tool handles, broom or brush bodies and handles, of wood; boot or shoe lasts and trees, of wood.**	kg	15	0	10	5	
44.18		ផលិតផលជាងឈើ និងផ្នែកនៃគ្រោងធ្លឹង សំរាប់សំណង់រាប់បញ្ចូលទាំងក្តារ កោសិកាក្តារបន្ទះសំរាប់ក្រាល និង គ្រឿងព្រំផ្ទះធ្វើពីឈើ	**Builders' joinery and carpentry of wood, including cellular wood panels, assembled parquet panels, shingles and shakes.**						
	4418.10.00	- បង្អួច ស្លាបទ្រិល និង គ្រោងបង្អួច	- Windows, French-Windows and their frames	kg	15	0	10	10	
	4418.20.00	- ទ្វារ និង គ្រោង ក្របទ្វារ	- Doors and their frames and thresholds	kg	15	0	10	10	
	4418.40.00	- គ្រឿងព្រំផ្ទះ	- Shuttering for concrete constructional work	kg	15	0	10	10	
	4418.50.00	- ក្តារកោសិកា ក្តារបន្ទះសំរាប់ក្រាល	- Shingles and shakes	kg	15	0	10	5	
	4418.60.00	- បង្គោល និងធ្នឹម	- Posts and beams	kg	15	0	10	5	
		- បន្ទះក្តារក្រាលដែលតម្លើងហើយ:	- Assembled flooring panels:						
	4418.71.00	- - សំរាលដែលមានតួរបតូចៗ	- - For mosaic floors	kg	15	0	10	5	
	4418.72.00	- - ផ្សេងទៀតដែលមានច្រើនស្រទាប់	- - Other, multilayer	kg	15	0	10	5	

	4418.79.00	- - ផ្សេងទៀត	- - Other	kg	15	0	10	5	
	4418.90	- ផ្សេងទៀត :	- Other :						
	4418.90.10	- - ក្រឿងស្រទាប់ជញ្ជាំង ធ្វើពីឈើ	- - Cellular wood panels	kg	15	0	10	10	
	4418.90.90	- - ផ្សេងទៀត	- - Other	kg	15	0	10	10	
44.19	4419.00.00	គ្រឿងធ្វើពីឈើ សម្រាប់តុ ឬ ផ្ទះបាយ	**Tableware and kitchenware, of wood.**	kg	15	0	10	0	
44.20		ឈើឆ្លាក់ និងឈើបង្កប់ ហឺបង្ខូច ប្រអប់ និងគ្រោង សម្រាប់គ្រឿងអលង្ការ ឬដបលិខិតឥលូធ្វើពីមាស និងគលើកឥលូប្រហាក់ប្រហែលធ្វើពីឈើ រូបចម្លាក់ និងវត្ថុផ្សេងទៀតសម្រាប់លំអរធ្វើពីឈើ គ្រឿងសង្ហារឹមធ្វើពីឈើមិនស្ថិតនៅក្នុងជំពូក ៩៤ ។	**Wood marquetry and inlaid wood; caskets and cases for jewellery or cutlery, and similar articles, of wood; statuettes and other ornaments of wood; wooden articles of furniture not falling in Chapter 94.**						
	4420.10.00	- រូបចម្លាក់ និងវត្ថុលំអរផ្សេងទៀត ធ្វើពីឈើ	- Statuettes and other ornaments, of wood	kg	15	0	10	0	
	4420.90	- ផ្សេងទៀត	- Other						
	4420.90.10	- - បន្ទះឈើសែលុយ	- -Cellular wood panels	kg	15	0	10	5	
	4420.90.90	- - ផ្សេងទៀត	- - Other	kg	15	0	10	5	
44.21		គ្រឿងឥលូ ផ្សេងទៀត ធ្វើពីឈើ	**Other articles of wood.**						
	4421.10.00	- ប្រហាក់ប្រហែលសំលៀកបំពាក់	- Clothes hangers	kg	15	0	10	0	
	4421.90	- ផ្សេងទៀត :	- Other :						
	4421.90.10	- - ចុង គ្រឿងស៊ី គ្រឿងស៊ីរចសរេ និងវត្ថុប្រហាក់ប្រហែល	- - Spools, cops and bobbins, sewing thread reels and the like	kg	15	0	10	0	
	4421.90.20	- - ឈើអប	- - Match splints	kg	15	0	10	0	
	4421.90.30	- - ស្លឹងឈើ ឬ ម្ជុលសម្រាប់គ្រឿងការពារនេជើង	- - Wooden pegs or pins for footwear	kg	15	0	10	0	
	4421.90.40	- - ឈើសម្រាប់ពោតស្ករគ្រាប់, ការ៉ាមែល និងស្លាបព្រាការ៉ាម	- - Candy-sticks, ice-cream sticks and ice-cream spoons	kg	15	0	10	0	
	4421.90.70	- - ដងបង់ ដូច សុំទិនយនការ និងការណែសុំទិនយនការ	- - Fans and handscreens, frames and handles therefor and parts of such frames and handles	kg	15	0	10	0	
	4421.90.80	- - ឈើចាក់ធ្មេញ	- - Toothpicks	kg	15	0	10	0	

		- - ផ្សេងទៀត:	- - Other:						
	4421.90.91	- - - បង្គាបសេះ ប្រសេះ	- - - Horse and bullock gear	kg	15	0	10	0	
	4421.90.92	- - - ខ្សែអង្កាំសម្រាប់ឧទ្ទិស	- - - Prayer beads	kg	15	0	10	0	
	4421.90.99	- - ផ្សេងទៀត	- - Other	kg	15	0	10	0	

ជំពូកទី ៤៥

Chapter 45

ស្បែកឈូ និងផលិតផលធ្វើពីស្បែកឈូ

Cork and articles of cork

ចំណាំជាមុនសិន

Notes

1.- ជំពូកនេះមិនរាប់បញ្ចូលទេ :

1.- This Chapter does not cover :

(a) ស្បែកជើង និងបំណែករបស់វាដែលជំពូក ៦៤

(a) Footwear or parts of footwear of Chapter 64;

(b) គ្រឿងបាក់ស្តាល និងបំណែករបស់វាដែលជំពូក ៦៥

(b) Headgear or parts of headgear of Chapter 65; or

(c) វត្ថុក្នុងជំពូក ៩៥ (ឧទា. ល្បែង ប្រដាប់លេង គ្រឿងលេង ឧបករណ៍កីឡាជាដើម)។

(c) Articles of Chapter 95 (for example, toys, games, sports requisites).

Head.	Tariff Code	ចំណងជើងទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
45.01		ស្បែកឈូជាតិមិនទាន់កែច្នៃ ឬគ្រាន់តែច្នៃខ្លះ- កំទេចស្បែកឈូ- ស្បែកឈូបែកគ្រាប់ ឬម្សៅវិញ ។	**Natural cork, raw or simply prepared; waste cork; crushed, granulated or ground cork.**						
	4501.10.00	- ស្បែកឈូជាតិមិនទាន់កែច្នៃ ឬគ្រាន់តែចាកច្នៃខ្លះ	- Natural cork, raw or simply prepared	kg	15	0	10	0	
	4501.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0	

ច្បាប់ស្តីពី អត្រាពន្ធគយ និង ពន្ធដារ ឆ្នាំ ២០២៤ ច្បាប់ស្តីពី អត្រាពន្ធគយ និង ពន្ធដារ ឆ្នាំ ២០២៤

45.02	4502.00.00	ឈើពុះឆ្នាចាប់ពីសសរបំបែកគ្រប់ទម្រង់ ឬក្រាស់ផ្ទៃរាងបួនជ្រុង ឬរាងបួនជ្រុងប្រហែល ជាឈើក្តឹប ឬបានដំរាងជាបន្ទះបួនជ្រុង ឬបន្ទះជ្រាំ ឬបន្ទះវែង (រាប់បញ្ចូលទាំងឈើ ដែលនៅមានគែមមុតស្រួច ឬគែមសម្រាប់ធ្វើជាឈើប្លុកសម្រាប់ធ្វើឆ្នាំ) ។	**Natural cork, debarked or roughly squared, or in rectangular (including square) blocks, plates, sheets or strip, (including sharp-edged blanks for corks or stoppers).**	kg	15	0	10	0	
45.03		ផលិតផលធ្វើពីឈើពុះឆ្នាធម្មជាតិ	**Articles of natural cork.**						
	4503.10.00	- ឈើពុះឆ្នា និង ឆ្នុកបង	- Corks and stoppers	kg	35	0	10	0	
	4503.90.00	- ឈើពុះឆ្នាផ្សេង	- Other	kg	35	0	10	0	
45.04		ឈើពុះឆ្នា (រាប់បញ្ចូលទាំងឈើពុះឆ្នាដែលបានធ្វើឡើងវិញ) និងផលិតផលធ្វើពីឈើពុះឆ្នាផ្សេងទៀត	**Agglomerated cork (with or without a binding substance) and articles of agglomerated cork.**						
	4504.10.00	- ប្លុក ផ្ទាំង សន្លឹក និងបន្ទះ ក៏ដូចជាសំណិតរាងបង្គោលមូល ទាំងឆាស	- Blocks, plates, sheets and strip/tiles of any shape; solid cylinders, including discs	kg	7	0	10	0	
	4504.90.00	- ឈើពុះឆ្នាផ្សេង	- Other	kg	35	0	10	0	

ជំពូកទី ៤៦

ផលិតផលតម្បាញ

កំណាត់សំគាល់ :

1.- ក្នុងជំពូកនេះឃាល "វត្ថុសំរាប់តម្បាញ" គឺវត្ថុដែលអាចត្បាញក្រចាញ់ទួលឬប្លាប្លក់ ប្រើប្រាស់តាមរបៀបប្រហាក់ប្រហែលគ្នា ។ ត្រូវចាត់ទុកជាវត្ថុខាងលើនេះបានរួមជាចំបើង ដើមស្រូល បូស្បី ប្របុស ព្រៃង រុយបង់ឈើ ខ្សែព្រ័ត្រ នៃរុក្ខជាតិផ្សេងៗ "រ៉ាហ្វីយ៉ា" ឬបានមកពីស្លឹកតូចច្រវែងឬបង់ដែលបានមកពីស្លឹក ឬសំណុំស្លឹក ឬបន្ទះ និងច្រង់គ្រាយប្រហាក់ប្រហែលវាយនភ័ណ្ឌវត្ថុធាតុមិនទាន់ ថ្លេចបន្ទះ ក្រដាសប៉ុនែ មិនមែនជាខ្សែព្រ័ត្រធ្វើពីស្បែកស្រស់ ឬស្បែកសំលាប់ រួចឬក៏ស្បែកផ្តុំបន្ទះ ហ៊ឺត សក់ សក់សេះ អំបោះ និងសរសៃវាយនភ័ណ្ឌ និងបន្ទះ ដែលមានទំរង់ដូចជំពូក ៥៤ ។

2.- មិនរាប់បញ្ចូលក្នុងជំពូកនេះទេ :

(a) វត្ថុសំរាប់ពាសជញ្ជាំងនៃទីតាំងលេខ ៤៨.១៤

(b) ខ្សែ ខ្សែព្រួរ និងពួរធួចៗ ក្រង ឬមិនក្រងទីតាំងលេខ ៥៦.០៧

(c) ស្បែកជើង មួកគ្រប់ប្រភេទ និងផ្នែករបស់វានៅជំពូក ៦៤ ឬ ៦៥

(d) យានយានា ឬតួសំរាប់យាន ដែលបានធ្វើអំពីផ្តៅ ដែក ជំពូក ៨៧

(e) វត្ថុនានានៃជំពូក ៩៤ (ឧទាហរណ៍ សង្ហារឹម គ្រឿងបំភ្លឺ)

Chapter 46

Manufactures of straw, of esparto or of other plaiting materials; basketware and wickerwork

Notes :

In this Chapter the expression "plaiting materials" means materials in a state or form suitable for plaiting, interlacing or similar processes; it includes straw, osier or willow, bamboos, rushes, reeds, strips of wood, strips of other vegetable material (for example, strips of bark, narrow leaves and raffia or other strips obtained from broad leaves), unspun natural textile fibres, monofilament and strip and the like of plastics and strips of paper, but not strips of leather or composition leather or of felt or nonwovens, human hair, horsehair, textile rovings or yarns, or monofilament and strip and the like of Chapter 54.

This Chapter does not cover :

Wall coverings of heading No. 48.14;

Twine, cordage, ropes or cables, plaited or not (heading No. 56.07);

Footwear or headgear or parts thereof of Chapter 64 or 65;

Vehicles or bodies for vehicles of basketware (Chapter 87); or

Articles of Chapter 94 (for example, furniture, lamps and lighting fittings).

ធានាភាព រហ័ស ច្បាស់លាស់ សេវាល្អ ក្នុងតម្លៃសមរម្យ ១៥ ឆ្នាំ ក្នុងវិស័យ សេវាប្រកាសពន្ធគយ

3.- តាមអត្ថន័យនៃចំណងជើងលេខ ៤៦.០១ ពាក្យថា "វត្ថុសំរាប់ស្មានឬគ្រឿងពេទ ពិការស្មាន" គឺជាវត្ថុប្រភាគ់ប្រភែលឬការថ្នឹតិវត្ថុធាតុសំរាប់ក្រង ឬតម្បាញ" គឺ វត្ថុដែលបង្កើតឡើងដោយវត្ថុធាតុសំរាប់តម្បាញ ដាក់ជាជួរតម្បាញ ឬក្តុដែល ចានពីគ្រឿងតម្បាញត្រួតគ្នា និងប្រមូលផ្តុំជាជាត្រួតគ្នា ដោយខ្សែចំណងនោះជា ចំណងនេះបានបង្កើតឡើងដោយសរសៃវាយនភីណូក់ដោយ។

For the purposes of heading No. 46 01, the expression "plaiting materials, plaits and similar products of plaiting materials, bound together in parallel strands" means plaiting materials, plaits and similar products of plaiting materials, placed side by side and bound together, in the form of sheets, whether or not the binding materials are of spun textile materials.

Head.	Tariff Code	ចំណាយចម្រុះទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
46.01		បន្ទះ និងវត្ថុប្រភាគ់ប្រភែលធ្វើពីវត្ថុធាតុសំរាប់ស្មាន ទោះបីជុំ ឬមិនផ្តុំជាបន្ទះ វត្ថុធាតុ សំរាប់ស្មាន បន្ទះ និងវត្ថុប្រភាគ់ប្រភែលេ ធ្វើពីវត្ថុធាតុសំរាប់ស្មានឬ តំរៀបរួមបច្ចុ រាងសំប៉ែតទោះសំរេច ឬមិនទាន់សំរេចក៏ដោយ (ការក្តុល ត្រួតគ្នា ធើឥតនិងថែម) ។	**Plaits and similar products of plaiting materials, whether or not assembled into strips; plaiting materials, plaits and similar products of plaiting materials, bound together in parallel strands or woven, in sheet form, whether or not being finished articles (for example, mats, matting, screens).**						
		- ការក្តុល ត្រួតគ្នាផ្ទាំងធើង និងថែមធ្វើពីរុក្ខជាតិ :	- Mats, matting and screens of vegetable materials :						
	4601.21.00	- - ពីបុស្ស	- - Of bamboo	kg	35	0	10	0	
	4601.22.00	- - ពីវល្លិ	- - Of rattan	kg	35	0	10	0	
	4601.29.00	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
		- ផ្សេងទៀត :	- Other :						
	4601.92	- - ពីបុស្ស	- - Of bamboo						
	4691.92.10	- - - បន្ទះ និងវត្ថុប្រភាគ់ប្រភែលេធ្វើពីវត្ថុធាតុសំរាប់ស្មាន ទោះបីជុំ ឬមិនផ្តុំជាបន្ទះ	- - - Plaits and similar products of plaiting materials, whether or not assembled or not assembled into strips.	kg	35	0	10	0	
	4601.92.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	

ច្បាប់ស្តីពី ពន្ធគយ និង រដ្ឋាករ ឆ្នាំ ២០១៦ ច្បាប់ស្តីពី ពន្ធគយ និង រដ្ឋាករ ឆ្នាំ ២០១៦

	4601.93	- - ចំបើ	- - Of rattan						
	4601.93.10	- - - បន្ទះ និងវត្ថុប្រហាក់ប្រហែលធ្វើពីវត្ថុធាតុសំណាប់ស្មាច្ចា ទោះបីផ្គុំ ឬមិនផ្គុំជាបន្ទះ	- - - Plaits and similar products of plaiting materials, whether or not assembled into strips.	kg	35	0	10	0	
	4601.93.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	4601.94	- - វត្ថុធាតុធ្វើពីវត្ថុជាតិរុក្ខជាតិផ្សេងទៀត	- - Of other vegetable materials:						
	4601.94.10	- - - បន្ទះ និងវត្ថុប្រហាក់ប្រហែលធ្វើពីវត្ថុធាតុសំណាប់ស្មាច្ចា ទោះបីផ្គុំ ឬមិនផ្គុំជាបន្ទះ	- - - Plaits and similar products of plaiting materials, whether or not assembled into strips.	kg	35	0	10	0	
	4601.94.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	4601.99	- - ផ្សេងទៀត :	- - Other :						
	4601.99.10	- - - ពរន្ទេច ក្រឡាប់ដួតជើង	- - -Mats and matting	kg	35	0	10	0	
	4601.99.20	- - - បន្ទះ និងវត្ថុប្រហាក់ប្រហែលធ្វើពីវត្ថុធាតុសំណាប់ស្មាច្ចា ទោះបីផ្គុំ ឬមិនផ្គុំជាបន្ទះ	- - - Plaits and similar products of plaiting materials, whether or not assembled into strips.	kg	35	0	10	0	
	4601.99.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
46.02		ផលិតផលសម្ភារៈច្នៃដោយផ្ទាល់ពីវត្ថុធាតុសំណាប់ស្មាច្ចា ឬរាត់តែម្តងដោយវត្ថុនៃទីតាំងលេខ ៤៦.០១ ផលិតផលធ្វើពីសាច្ចូនត្នោត ។	**Basketwork, wickerwork and other articles, made directly to shape from plaiting materials or made up from goods of heading No. 46.01; articles of loofah.**						
		- ធ្វើពីវត្ថុជាតិ :	- Of vegetable materials :						
	4602.11.00	- - ពីបុស្ស	- - Of bamboo	kg	35	0	10	0	
	4602.12.00	- - ពីចំបើ	- - Of rattan	kg	35	0	10	0	
	4602.19.00	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
	4602.90.00	- ផ្សេងទៀត	- other	kg	35	0	10	0	

ផ្នែកទី X

ម្សៅឈើ
ឬវត្ថុធាតុមានសរសៃសែសុយឡូសផ្សេងទៀត ក្រដាស
និងក្រដាសកាតុងដែលត្រូវកែច្នៃឡើងវិញ (សំណល់
និងកាកសំណល់) ក្រដាស ក្រដាសកាតុង
និងផលិតផលរបស់វា

Section X

Pulp of wood or of other fibrous cellulosic material; recovered (waste and scrap) paper or paperboard; paper and paperboard and articles there of

ជំពូកទី ៤៧

ម្សៅឈើ ឬវត្ថុធាតុមានសរសៃសែសុយឡូសផ្សេងៗទៀត
ក្រដាស និងក្រដាសកាតុងដែលត្រូវកែច្នៃឡើងវិញ
(សំណល់ និងកាកសំណល់)

Chapter 47

Pulp of wood or of other fibrous cellulosic material ; recovered (waste and scrap) paper or paperboard

កំណត់សំគាល់ :

Note :

1.-

តាមអត្ថន័យនៃចំណាំងលេខ ៤៧.០២ ពាក្យ "ម្សៅឈើគីមីពែលលោយ" គឺជាម្សៅឈើ គីមីពែលមានភាគម្សៅមិនរលាយ៩២% នៃទំងន់សមាសធាតុ ឬលើសពីតជាទំងន់ ។ បើសិនជាម្សៅឈើមានស្ពឹត ឬសុលហ្វាត៨៨ % ឬលើសពីតជាទំងន់ ។ បើសិនជាម្សៅឈើមានប៊ីស៊ុលហ្វីត ហើយមួយម៉ោងក្រោយមកគេយកទៅជាក់ក្នុងល្បាយស្ពឹតកូស្ទិកដែលមានសូដ្យូមអ៊ីដ្រូស៊ីត ១ណាប្រ៊ែត ១៨% ក្នុងសីតុណ្ហភាព២០°c រួចមកចំពោះម្សៅឈើមានប៊ីស៊ុលហ្វីត ដែលមានជាពិសេសមិនលើសពី០,១៥% គឺតជាទំងន់។

For the purposes of heading No. 47.02, the expression "chemical wood pulp, dissolving grades" means chemical wood pulp having by weight an insoluble fraction of 92 % or more for soda or sulphate wood pulp or of 88 % or more for sulphite wood pulp after one hour in a caustic soda solution containing 18 % sodium hydroxide (NaOH) at 20 °C, and for sulphite wood pulp an ash content that does not exceed 0.15 % by weight.

Head.	Tariff Code	ចំណោទទុនទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
47.01	4701.00.00	ម្សៅឈើមេកានិច	**Mechanical wood pulp.**	kg	7	0	10	0	
47.02	4702.00.00	ម្សៅឈើគីមីរលាយ	**Chemical wood pulp, dissolving grades.**	kg	7	0	10	0	
47.03		ម្សៅឈើគីមីមានស្ពឹតឬស៊ុលហ្វាត ក្រៅពីម្សៅរលាយ	**Chemical wood pulp, soda or sulphate, other than dissolving grades.**						
		- ពៅ ឬមិនទាន់ធ្វើអោយស :	- Unbleached :						
	4703.11.00	- - កូនីហ្វែរ	- - Coniferous	kg	7	0	10	0	
	4703.19.00	- - ក្រៅពីកូនីហ្វែរ	- - Non-coniferous	kg	7	0	10	0	
		- ពាក់កណ្តាលស ឬ ពានធ្វើអោយស :	- Semi-bleached or bleached:						
	4703.21.00	- - កូនីហ្វែរ	- - Coniferous	kg	7	0	10	0	
	4703.29.00	- - ក្រៅពីកូនីហ្វែរ	- - Non-coniferous	kg	7	0	10	0	
47.04		ម្សៅឈើគីមីមានស៊ុលហ្វីត ក្រៅពីម្សៅរលាយ	**Chemical wood pulp, sulphite, other than dissolving grades.**						

		- មិនចាត់ធ្វើអោយស :	- Unbleached :						
	4704.11.00	- - កូនីហ្វែរ	- - Coniferous	kg	7	0	10	0	
	4704.19.00	- - ក្រៅពីកូនីហ្វែរ	- - Non-coniferous	kg	7	0	10	0	
		- ពាក់កណ្តាលស ឬបានធ្វើអោយស :	- Semi-bleached or bleached :						
	4704.21.00	- - កូនីហ្វែរ*	- - Coniferous	kg	7	0	10	0	
	4704.29.00	- - ក្រៅពីកូនីហ្វែរ	- - Non-coniferous	kg	7	0	10	0	
47.05	4705.00.00	**ម្សៅឈើដែលទំលាំងើការផលិតដោយមេកានិក និងគីមី**	**Wood pulp obtained by a combination of mechanical and chemical pulping processes.**	kg	7	0	10	0	
47.06		**ម្សៅធ្វើពីវត្ថុសរសៃសែលុបឡូសផ្សេងទៀត**	**Pulps of fibres derived from recovered (waste and scrap) paper or paperboard or of other fibrous cellulosic material.**						
	4706.10.00	- ម្សៅធ្វើពីសរសៃកប្បាសខ្លីៗ	- Cotton linters pulp	kg	7	0	10	0	
	4706.20.00	- ម្សៅសែលុបបានពីកំទេច និងសំណល់ក្រដាស ឬក្រដាសកាតុង	- Pulps of fibres derived from recovered (waste and scrap) paper or paperboard	kg	7	0	10	0	
	4706.30.00	- ផ្សេងទៀតពីឫស្សី	- Other of Bamboo	kg	7	0	10	0	
		- ផ្សេងទៀត :	- Other :						
	4706.91.00	- - មេកានិច	- - Mechanical	kg	7	0	10	0	
	4706.92.00	- - គីមី	- - Chemical	kg	7	0	10	0	
	4706.93.00	- - ពាក់កណ្តាលគីមី	- - Semi-chemical	kg	7	0	10	0	
47.07		**កំទេច និងសំណល់ក្រដាស ឬក្រដាសកាតុង**	**Recovered (waste and scrap) paper or paperboard.**						
	4707.10.00	- ពីក្រដាស ឬក្រដាសកាតុងរលៅ ឬ ពីក្រដាស ឬក្រដាសកាតុងលេក	- unbleached kraft paper or paperboard or of corrugated paper or paperboard	kg	35	0	10	0	
	4707.20.00	- ពីក្រដាស ឬក្រដាសកាតុងផ្សេងទៀតជាពិសេសពីម្សៅគីមីស មិនអោយពណ៌ ។	- Of other paper or paperboard made mainly of bleached chemical pulp, not coloured in the mass	kg	35	0	10	0	

	4707.30.00	- ពីក្រដាស ឬក្រដាសកាតុងជាន់ដាំពីសេសពីឡេរេកានិច (ការសែត ទស្សនាវដ្តី និងឯកសារបោះពុម្ពប្រចាំកាលប្រចាំឆ្នាំ) ។	- Of paper or paperboard made mainly of mechanical pulp (for example, newspapers , journals and similar printed matter)	kg	35	0	10	0	
	4707.90.00	- ផ្សេងៗរាប់បញ្ចូលទាំងកំទេច និងសំណល់ចិនមានគុណភាពមិនសមរម្យ	- Other, including unsorted waste and scrap	kg	35	0	10	0	

ជំពូកទី ៤៨

ក្រដាស និងក្រដាសកាតុង ផលិតផលធ្វើពីមៀសក្រដាស ធ្វើពីក្រដាស ឬក្រដាសកាតុង

Chapter 48

Paper and paperboard; articles of paper pulp, of paper or of paperboard

កំណាត់សំគាល់

Notes

1.- អត្ថន័យនៃជំពូកនេះ លើកលែងតែបរិបទទាំងឡាយនៃលក្ខខណ្ឌការប៉ុណ្ណោះ យោងលើពាក្យ"ក្រដាស" រួមបញ្ចូលការយោងនៃក្រដាសកាតុង (ដែលមានតម្រាស់ និងទម្ងន់ក្នុង ១ម^2)

For the purposes of this Chapter, except where the context otherwise requires, a reference to "paper" includes references to paperboard (irrespective of thickness or weight per m^2)

2.- ជំពូកនេះមិនរាប់បញ្ចូល :

This Chapter does not cover :

(a) ប្រភាប់ប្រើការក្នុងជំពូកទី ៣០

Articles of Chapter 30;

(b) ក្រដាសសំរាប់ចោះត្រាដែក ក្នុងទីតាំងលេខ ៣២.១២

Stamping foils of heading No. 32.12;

(c) ក្រដាសក្រអូប ក្រដាសសំរាប់ជ្រលក់ ឬលាប ជាដើម (ជំពូក ៣៣)

Perfumed papers or papers impregnated or coated with cosmetics (Chapter 33);

(d) ក្រដាស ឬសំឡីសែលុយឡូស ជ្រលក់ លាប គាសដោយសាប៊ូ ឬគ្រឿងសំអាង ទីតាំងលេខ ៣៤.០១ ដោយប៊ៃក្រម ក្រមួន ឬរបស់ដែលផ្សំមានលក្ខណៈស្រដៀងគ្នា ទីតាំងលេខ ៣៤.០៥ ។

Paper or cellulose wadding impregnated, coated or covered with soap or detergent (heading No. 34.01), or with polishes, creams or similar preparations (heading No. 34.05);

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ១៩ ឧសភា ជ.ស

(e)	ក្រដាស និងក្រដាសកាតុងសំរាប់ថ្ពិត ឬជាប់រួបក្នុងទីតាំងលេខ ៣៧.០១ ទៅ ៣៧.០៤	Sensitised paper or paperboard of headings Nos. 37.01 to 37.04;
(f)	ក្រដាសផ្ទុកជាតិមន្ទាល់សំរាប់ធាតវិភាគ ឬទឹកាសោធន៍ (ទីតាំងលេខ ៣៨.២២)	Paper impregnated with diagnostic or laboratory reagents (heading No. 38.22);
(g)	វត្ថុធាតុជាតិប្លាស្ទិកតំរៀបជាស្រទាប់ដែលមានក្រដាស ឬក្រដាសកាតុងផលិតផលែលធ្វើឡើងដោយក្រដាសរលោង ដោយក្រដាសកាតុងណាម ឬការសដោយអង្គធាតុផ្លាស្ទិក ការលើដែកតំរាស់របស់ជាលើសពាក់កណ្តាលនៃតំរាស់សរុប និងប្រដាប់ប្រដាដែលធ្វើឡើងដោយអង្គធាតុខាងលើ លើកលែងតែក្រដាសសំរាប់បិទជញ្ជាំងដែលចែងក្នុងទីតាំងលេខ ៤៨.១៤ (ជំពូក ៣៩)។	Paper-reinforced stratified sheeting of plastics, or one layer of paper or paperboard coated or covered with a layer of plastics, the latter constituting more than half the total thickness, or articles of such materials, other than wall coverings of heading No. 48.14 (Chapter 39);
(h)	ប្រដាប់ប្រដាដែលចែងនៅក្នុងទីតាំងលេខ ៤២.០២ (ដូចជាប្រដាប់ប្រដាសំរាប់ធ្វើដំណើរជាដើម)	Articles of heading No. 42.02 (for example, travel goods);
(ij)	ប្រដាប់ប្រដាដែលចែងនៅក្នុងជំពូក ៤៦ (វត្ថុដែលបានពីការត្បាញ ឬក្រង)	Articles of Chapter 46 (manufactures of plaiting material);
(k)	សរសៃក្រដាស និងគ្រឿងវាយនភ័ណ្ឌពីខ្សែសរសៃក្រដាស (ផ្នែក XI) ។	Paper yarn or textile articles of paper yarn (Section XI);
(l)	ប្រដាប់ប្រដាដែលចែងនៅក្នុងជំពូក ៦៤ ឬ ៦៥	Articles of Chapter 64 or Chapter 65;
(m)	ផលិតផលសំរាប់ខាត់ដែលលាបក្រដាស ឬក្រដាសកាតុងទីតាងលេខ ៦៨.០៥ និងថ្មមិកា ដែលលាបលើក្រដាស ឬក្រដាសកាតុងទីតាំងលេខ ៦៨.១៤ ។ ជាមួយគេហើយ ក្រដាស និងក្រដាសកាតុងដែលពាសដោយម្សៅមីកាត្រូវបញ្ចូលក្នុងជំពូកនេះ ។	Abrasive paper or paperboard (heading No. 68.05) or paper- or paperboard-backed mica (heading No. 68.14) (paper and paperboard coated with mica powder are, however, to be classified in this Chapter);

(n)	សន្លឹក និងបន្ទះដែលគាស្តើងដែលមានលាយក្រដាស ឬក្រដាសកាតុងជាខ្នង (ផ្នែកទី XV)	Metal foil backed with paper or paperboard (Section XV);
(o)	ប្រដាប់ប្រដាដែលមានចែងនៅក្នុងចំណាត់ថ្នាក់លេខ ៩២.០៩ ។	Articles of heading No. 92.09; or
(p)	ប្រដាប់ប្រដានៅក្នុងជំពូក៩៥ ដូចជាគ្រឿងប្រដាប់លេង គ្រឿងកីឡា ឬក្នុងជំពូក ៩៦ (ដូចជាខ្សៃ)	Articles of Chapter 95 (for example, toys, games, sports requisites) or Chapter 96 (for example, buttons).

3.- បេះបិទតាមកំណត់សំគាល់ទី ៦ ត្រូវរាប់បញ្ចូលក្នុងចំណាត់ថ្នាក់លេខ ៤៨.០១ ទៅ ៤៨.០៥ ក្រដាសនិងក្រដាសកាតុងដែលបានឆ្លងកាត់ការកិនឱ្យរាបស្មើឬតាមរបៀបផ្សេងៗ ដូចជាការខាត់ ការធ្វើឱ្យរលោង ការខាត់ឱ្យភ្លឺ ឬ តាមរបៀបដែលមានលក្ខណៈស្រដៀងគ្នាក្នុងការធ្វើឱ្យសំរេច ឬការខាត់ផ្ទៃដោយប្រើម៉ាស៊ីនក្រមទាំងក្រដាសសំឡីសែលុយឡូស និងក្រណាត់ដែលធ្វើឡើងដោយសរសៃសែលុយឡូសជ្រលក់ពណ៌ ឬលាបម្ជុតចេ ជាសាច់ផ្ទៃតែវ (តាមបែបផ្សេងៗនៃផ្ទៃ)។ ប្រសិនជាក្រដាសកាតុង សែលុយឡូស និងក្រណាត់ដែលធ្វើឡើងដោយសរសៃសែលុយឡូសដែលធ្វើឡើងតាមរបៀបវិធីផ្សេងទៀតនិងមិនត្រូវ ចាត់ទុកក្នុងចំណុចនេះទេលើកលែងតែបទបញ្ញត្តិផ្ទុយនឹងចំណាត់ថ្នាក់លេខ ៤៨.០៣ ។

Subject to the provisions of Note 6, headings Nos. 48.01 to 48.05 include paper and paperboard which have been subjected to calendering, super-calendering, glazing or similar finishing, false water-marking or surface sizing, and also paper, paperboard, cellulose wadding and webs of cellulose fibres, coloured or marbled throughout the mass by any method. Except where heading No. 48.03 otherwise requires, these headings do not apply to paper, paperboard, cellulose wadding or webs of cellulose fibres which have been otherwise processed.

4.- នៅក្នុងជំពូកនេះ "ក្រដាសកាសែត" គឺក្រដាសមិនរលោងមិនមានពណ៌ ជាប្រភេទប្រើក្នុងការបោះពុម្ពកាសែតដែលមានចំងាយយ៉ាងតិច ៦៥% នៃជាតិសរសៃសរុបដែលផ្សំឡើងដោយសរសៃសេលើដែលបំលែងតាមរបៀបដែនមេកានិកឬមេកានិកគីមីដែលមានលាបកាវ ឬលាបកាវ Parker print (1Mpa) លើមុខនីមួយៗលើសពី ២,៥ មីក្រូម៉ែត្រមានទម្ងន់ចាប់ពី ៤០ g/m² និងមិនលើសពី ៦៥ g/m² ។

In this Chapter the expression "newsprint" means uncoated paper of a kind used for the printing of newspapers, of which not less than 65 % by weight of the total fibre content consists of wood fibres obtained by a mechanical or chemi-mechanical process, unsized or very lightly sized, having a surface roughness Parker Print Surf (1 MPa) on each side exceeding 2.5 micrometres (microns), weighing not less than 40 g/m² and not more than 65 g/m².

5.-

	ក្រៅពីក្រដាស និងក្រដាសកាតុងធ្វើដោយដៃ និងសន្លឹក(ក្រដាសជួតដៃ) ចំណាត់លេខ ៤៨.០២ រាប់បញ្ចូលក្រដាសនិងក្រដាសកាតុងដែលធ្វើឡើងជាអាទិ៍ពីម្សៅឱ្យសឬម្សៅបានមកតាមរបៀបមេកានិកហើយបំពេញតាមលក្ខខ័ណ្ឌណាមួយនៃលក្ខខ័ណ្ឌខាងក្រោមនេះ ។	In addition to hand-made paper and paperboard, heading No. 48.02 covers only paper and paperboard made mainly from bleached pulp or from pulp obtained by a mechanical process and satisfying any of the following criteria :
	ចំពោះក្រដាស ឬក្រដាសកាតុងដែលមានទំងន់មិនលើសពី ១៥០ក្រាម/ម^{២} :	For paper or paperboard weighing not more than 150 g/m^{2}:
(a)	មានសរសៃបានមកពីការធ្វើតាមរបៀបមេកានិក ១០% ឬលើស :	containing 10 % or more of fibres obtained by a mechanical process, and
	១/. ទំងន់មិនលើសពី ៨០ ក្រាម/ម^{២}	weighing not more than 80 g/m^{2}, or
	២/. ដែលជាក់ពណ៌ទាំងស្រុង	coloured throughout the mass; or
(b)	មានចំនួនផេះលើសពី ៨% និង :	containing more than 8 % ash, and
	១/. មានទំងន់មិនលើសពី ៨០ក្រាម/ម^{២}	weighing not more than 80 g/m^{2}, or
	២/. ដែលជាក់ពណ៌ទាំងស្រុង	coloured throughout the mass; or
(c)	មានជាតិផេះលើសពី ៣% និងមានសន្ទស្សន៍ជាតិស (តាមរយៈការបញ្ចាំងពន្លឺ) ស្មើឬលើស ៦០%	containing more than 3 % ash and having a brightness of 60 % or more; or
(d)	មានជាតិផេះលើសពី ៣% តែមិនឱ្យលើស ៨% មានសន្ទស្សន៍ជាតិស (តាមរយៈការបញ្ចាំងពន្លឺ) តិចជាង ៦០% និងមានភាពតន់ និងការផ្ទុះមិនឱ្យលើសពី ២,៥kPa/m^{2} /g។	containing more than 3 % but not more than 8 % ash, having a brightness less than 60 %, and a burst index equal to or less than 2.5 kPa m^{2}/g; or
(e)	មានជាតិផេះ ៣% ឬតិចជាងដែលមានសន្ទស្សន៍ជាតិស (តាមរយៈការបញ្ចាំងពន្លឺ) ៦០% ឬលើស និងមានភាពតន់ខែការផ្ទុះមិនឱ្យលើសពី ២,៥ kPa/m^{2} /g ។	containing 3 % ash or less, having a brightness of 60 % or more and a burst index equal to or less than 2.5 kPa m^{2}/g.

	សម្រាប់ក្រដាស ឬក្រដាសកាតុងដែលមានតម្លៃលើសពី ១៥០ក្រ/ម^2	For paper or paperboard weighing more than 150 g/m^2:
(a)	ដែលជាក់ពណ៌ទាំងស្រុង	coloured throughout the mass; or
(b)	មានសន្ទស្សន៍ជាតិស (តាមរយៈការបញ្ចាំងពន្លឺ) ៦០% ឬលើស	having a brightness of 60 % or more, and
1	កំរាស់មិនឱ្យលើសពី ២២៥ មីក្រូម៉ែត្រ (មីក្រុង)	a caliper of 225 micrometres (microns) or less, or
2	កំរាស់លើស ២២៥ មីក្រូម៉ែត្រ (មីក្រុង) ប៉ុន្តែមិនឱ្យលើស ៥០៨ មីក្រូម៉ែត្រ (មីក្រុង) និងមានជាតុផេះលើស ៣% ។ ។	a caliper more than 225 micrometres (microns) but not more than 508 micrometres (microns) and an ash content more than 3 %; or
(c)	មានសន្ទស្សន៍ជាតិស តាមរយៈការបញ្ចាំងពន្លឺ (តិចជាង ៦០% កំរាស់មិនឱ្យលើសពី ២៥៤ មីក្រូម៉ែត្រ (មីក្រុង) និងជាតុផេះលើសពី ៨% ។ ទីតាំងលេខ ៤៨.០២ មិនរាប់បញ្ចូលនូវក្រដាស និងក្រដាសកាតុងសំរាប់ប្រោះ (ដោយរាប់បញ្ចូលទាំងក្រដាសខ្ចប់តែ) ក្រដាស និងក្រដាសកាតុង ហ្វិត ។	having a brightness of less than 60 %, a caliper of 254 micrometres (microns) or less and an ash content more than 8 %. Heading No. 48.02 does not, however, cover filter paper or paperboard (including tea-bag paper) or felt paper or paperboard.
6.-	ក្នុងជំពូកនេះ (ក្រដាស និងក្រដាសកាតុងក្រាហ្វត់) គឺក្រដាស និងក្រដាសកាតុងទាំងឡាយដែលមានទំងន់មិនតិចជាង ៨០% នៃជាតុសរុបពីជាតិសរសៃសរុបដែលធ្វើឡើងដោយសរសៃបានដោយវិធីគីមីដែលមានស៊ុលហ្វាត ឬសូដ។	In this Chapter "kraft paper and paperboard" means paper and paperboard of which not less than 80 % by weight of the total fibre content consists of fibres obtained by the chemical sulphate or soda processes.
7.-	លើកលែងតែលក្ខខ័ណ្ឌដែលបានចែងផ្សេងពីនេះ ពាក្យក្រដាស ក្រដាសកាតុង សំឡីសែលុយឡូស និងក្រណាត់ធ្វើពីសរសៃសែលុយឡូសដែលអាចបញ្ចូលក្នុងទីតាំងពីរ ឬច្រើនតែទីតាំងលេខ ៤៨.០៩ ទៅ ៤៨.១៩ ត្រូវបានគេចាត់ទៅក្នុងទីតាំងណាមួយក្នុងចំណោមទីតាំងនោះដែលមានលំដាប់លេខចុងក្រោយក្នុងនាមវិលី ។	Except where the terms of the headings otherwise require, paper, paperboard, cellulose wadding and webs of cellulose fibres answering to a description in two or more of the headings Nos. 48.01 to 48.11 are to be classified under that one of such headings which occurs last in numerical order in the Nomenclature.

៨.-	(A)	ក្រមួយបន្ទុលក្នុងចំណាំងលេខ ៤៨.០១, ៤៨.០២, ៤៨.០៤ ទៅ ៤៨.០៨, ៤៨.១០ និង ៤៨.១១ តែក្រមាស ក្រមាសកាតុង សំឡីសែលុយឡូស និងក្រណាត់ធ្វើពីសរសៃសែលុយឡូសដែលបង្ហាញតទៅក្នុងចំណាំងខាងក្រោមនេះ :	Headings Nos. 48.01, 48.02, 48.04 to 48.08, 48.10 and 48.11 apply only to paper, paperboard, cellulose wadding and webs of cellulose fibres :
	(a)	ជាបង់ ឬជាប៊ូប៊ីនដែលទទឹងរបស់វាលើសពី ១៥ ស.ម	in strips or rolls of a width exceeding 15 cm; or
	(b)	ជាក្រមាសមានរាងជាការ ឬបន្ទះក្រូចឆ្មារ ដែលជ្រុងរបស់វាម៉ាំងហោចណាស់លើសពី៣៦ស.ម និងជ្រុងមួយទៀតលើសពី ១៥ស.ម ក្នុងភាពមិនបត់ ។	in rectangular (including square) sheets with one side exceeding 36 cm and the other side exceeding 15 cm in the unfolded state.
៩.-		ពាក្យ (ក្រមាសតុំខ្លួន រួបលំអ និងក្រឿងក្តុងផ្សេងទៀតប្រើសំរាប់ជាសេចក្តីក្រាំង) ចែងក្នុងចំណាំងលេខ ៤៨.១៤ គឺ :	For the purposes of heading No. 48.14, the expression "wallpaper and similar wall coverings" applies only to:
	(a)	ក្រមាសមានទម្រង់ជារមូរដែលមានទទឹងស្មើ ឬលើសពី ៤៥ សង់ទីម៉ែត្រ ប៉ុន្តែបណ្តោយមិនលើសពី ១៦០ ស.ម ប្រើសំរាប់តែលំអជញ្ជាំង និងពិដានមាន :	Paper in rolls, of a width of not less than 45 cm and not more than 160 cm, suitable for wall or ceiling decoration :
	(i)	រួបលំអ ដូចអក្សរបោះពុម្ព ឬជ្រលក់ពណ៌ ឬតុំតុបតែងលំអផ្ទៃខាងលើទោះជាសាប ឬភាសផ្លាស្ទិកថ្លាពីលើផ្ទៃសំរាប់ការពារ ។	Grained, embossed, surface-coloured, design-printed or otherwise surface-decorated (e.g., with textile flock), whether or not coated or covered with transparent protective plastics;
	(ii)	ផ្ទៃរបស់វាមានលក្ខណៈជាគ្រាប់ៗ ជាឧទាហរណ៍ កំទេចឈើ ឬជាចំបើង ។ ល ។	With an uneven surface resulting from the incorporation of particles of wood, straw, etc.;
	(iii)	លាប ឬភាសពីលើផ្ទៃខាងមុខដោយជាតិផ្លាស្ទិកលើស្រទាប់ផ្ទៃថ្លាស្ទិកដែលមានភាពជាគ្រាប់ៗ មានជ្រលក់ពណ៌ ចោះពុម្ពជាក្បាច់ ឬលំអផ្សេងៗទៀត ។	Coated or covered on the face side with plastics, the layer of plastics being grained, embossed, coloured, design-printed or otherwise decorated; or
	(iv)	ពាស ឬបិទផ្ទៃខាងលើដោយវត្ថុតម្បាញ ឬក្បាច់ ជាផ្ទៃស្រម ។	Covered on the face side with plaiting material, whether or not bound together in parallel strands or woven;

(b)	បន្ទះតាសែម ប្រុងធ្វើពីក្រដាស ដែលគេចាត់ទុកជាវាមនេលក្តួលៈប្លួចខាងលើ ទោះវាមានជារាងតុំរួមក៏ដោយ ដែលគេយកវាទៅតាសលំអជញ្ជាំង ឬពិដាន ។	Borders and friezes, of paper, treated as above, whether or not in rolls, suitable for wall or ceiling decoration:
(c)	វត្ថុសំរាប់តាសជញ្ជាំង ធ្វើពីក្រដាស ដែលបង្កើតឡើងដោយចាំណាំជារង្វេងនាងជារួម ឬជាសន្លឹក ជាប្រភេទចោះពុម្ពចេញជារូបភាព ឬជាផ្ទាំងតំនូរ ឬជាក្បាច់សំរាប់តាំងលំអតាមជញ្ជាំង ។	Wall coverings of paper made up of several panels, in rolls or sheets, printed so as to make up a scene, design or motif when applied to a wall.
	គ្រប់វត្ថុដែលធ្វើពីក្រដាស ក្រដាសកាតុង ដែលគេយកទៅប្រើប្រាស់ជារបស់សំរាប់កំរាល ឬសំរាប់បិទតាសជញ្ជាំង ត្រូវចូលនិតាំងលេខ ៤៨.១៤ ។	Products on a base of paper or paperboard, suitable for use both as floor coverings and as wall coverings, are to be classified in heading No. 48.15.
10.-	និតាំងលេខ ៤៨.២០ មិនគ្រប់បណ្តុលន្លូវសន្លឹក បន្ទះមិនទាន់ពុំមានខ្នាតទោះជាប្រភេទចោះពុម្ពប្រថាប់ ឬប្រភេទគេចោះរន្ធលើផ្ទៃរបស់វាក៏ដោយ ។	Heading No. 48.20 does not cover loose sheets or cards, cut to size, whether or not printed, embossed or perforated.
11.-	និតាំងលេខ ៤៨.២៣ ន្លូវក្រដាសធម្មតានិងក្រដាសកាតុងណាដែលគេមានចោះរន្ធសំរាប់ប្រើនៅក្នុងម៉ាសុីនតាមសាកសារ (Jacquard) ក្រឿងប្រហាក់ប្រហែល និងក្រដាសរុះ ។	Heading No. 48.23 applies, inter alia, to perforated paper or paperboard cards for Jacquard or similar machines and paper lace.
12.-	លើកលែងន្លូវវត្ថុដែលបែងក្នុងនិតាំងលេខ ៤៨.១៤ និង ៤៨.២១ ក្រដាស និងក្រដាសកាតុង សំឡីសែលុយឡូស និងវត្ថុធ្វើពីវត្ថុទាំងនោះ និងត្រូវចាត់ទុកបែងក្នុងជំពូក ៤៩ ហើយមានភាពពុម្ព ឬគួរ ហើយជាទេភាពបន្ទាប់បន្សំក្នុងការប្រើប្រាស់ដំបូងរបស់វាត្រូវចូលក្នុងជំពូក ៤៩ ។	Except for the goods of heading No. 48.14 or 48.21, paper, paperboard, cellulose wadding and articles thereof, printed with motifs, characters or pictorial representations, which are not merely incidental to the primary use of the goods, fall in Chapter 49.

កំណាត់ន្លូវចាត់និតាំងរង **Subheading Notes.**

1.-

